## តើមានអ្វីកើតឡើង បើដៃគូរបស់ខ្ញុំត្រូវរកឃើញមានទោស?

បើដៃគូរបស់អ្នកត្រូវរកឃើញមានទោស ពីបទប្រព្រឹត្តអំពើហិង្សានៅក្នុងគ្រួសារ គេអាចត្រូវកាត់ទោសឲ្យទទួលការឲ្យឱវាទ ត្រួតត្រាមើលដោយភ្នាក់ងារផ្នែកព្យួរទោសមានលក្ខខ័ណ្ឌ ឬការដោះលែងមានលក្ខខណ្ឌពីប៉ូលិស ហើយនិងអាចជាប់ពន្ធនាគារទៀតផង ។ តុលាការអាចចេញដីកាពន្យាពេលនៃដីកាហាមទាក់ទងលើសពីពេលធម្មតាដើម្បីជាការការពាររបស់អ្នក ។

## តើមានអ្វីទៀតដែលខ្ញុំត្រូវធ្វើ ដើម្បីឲ្យមានសុវត្ថិភាព ?

អ្នកអាចប្តឹងសុំសំរាប់ឲ្យមានដីកាការពារ ។ ដីកាបែបនេះអាចហាមមិនឲ្យដៃគូចូលក្នុងផ្ទះរបស់អ្នក ហាមប្រាមគេពីការរុកគួនរំខាន ឬទាក់ទងអ្នក ហាមប្រាមគេពីការយកកូនរបស់អ្នកចេញពីរដ្ឋវ៉ាស៊ិនតោន និងបង្កើតកាលវិភាគបណ្តោះអាសន្នសំរាប់ការមកសួរសុខទុក្ខ ។ អ្នកមិនចាំបាច់ជាសញ្ជាតិអាមេរិក ឬមានប័ណ្ណពណ៌បៃតងសំរាប់ទទួល ដីកាការពារទេ ។ អ្នកអាចប្តឹងសុំដីកាបែបនេះនៅ តុលាការដែលនៅជិត លំនៅដ្ឋានអ្នក ។ មានអ្នកជួយគាំទ្រពិសេសនឹងជួយអ្នក ។

អ្នកអាចធ្វើការទាក់ទងទៅទីភ្នាក់ងារមួយក្នុងចំណោមទីភ្នាក់ងារនានាដែលមានរាយឈ្មោះនៅក្រោម បញ្ជីឈ្មោះធនធានសហគមន៍ ។ ទីភ្នាក់ងារទាំងអស់ នេះគឺជាទីភ្នាក់ងារឯកជន និងមិនមែនជាចំណែកនៃរដ្ឋាភិបាលឡើយ ។ អ្នកជួយគាំទ្រ អាចជួយអ្នកឲ្យបង្កើតផែនការសុវត្ថិភាពមួយ និងរកសំលៀកបំពាក់ ចំណីអាហារ ជម្រកនិងការឧបត្ថម្ភ ។

អ្នកអាចនិយាយជាមួយបុគ្គលណាម្នាក់ដែលអ្នកទុកចិត្ត ដែលយល់ស្ថានភាពរបស់អ្នក និងជាអ្នកអាចជួយអ្នក ។

អ្នកអាចសិក្សាអំពីសិទ្ធិរស់នៅ និងទទួលជំនួយផ្នែកច្បាប់ដោយផ្ទាល់ពីទីភ្នាក់ងារមួយដែលមានរាយឈ្មោះនៅខាងក្រោម ។

## ធនធានសហគមន៍

ទីភ្នាក់ងារដែលមានរាយឈ្មោះខាងក្រោម គឺជាទីភ្នាក់ងារឯកជនទាំងអស់ និងមិនមែនជាចំណែកនៃរដ្ឋាភិបាល ឬក្រសួង INS ឡើយ ។

- **Abused Deaf Women's Advocacy Services**
  (TDD គនិងថ្ងប៉ុណ្ណោះ)
  206-236-3134
- **Asian/Pacific Islander Women & Family Safety Center**
  206-467-9976
- **Chaya** (សំរាប់ស្ត្រីមកពីអាស៊ីភាគអាគ្នេយ៍)
  206-325-0325
- **Consejo Counseling & Referral Service**
  206-461-4880
- **Domestic Abuse Women's Network (DAWN)**
  425-656-7867
- **Eastside Domestic Violence Program**
  425-746-1940 ឬ 1-800-827-8840
- **Jewish Family Service**
  206-461-3240
- **New Beginnings**
  206-522-9472
- **Northwest Network for Bisexual, Trans, & Lesbian Survivors of Abuse**
  206-568-7777, 206-517-9670 (ទុកបណ្តាំតាមទូរសព្ទ)
- **Refugee Women's Alliance**
  (បំរើ 14 ភាសានៅក្នុងសហគមន)
  206-721-0243
- **Seattle Indian Health Board**
  206-324-9360, ext. 802
- **YWCA**
  206-568-7845 ឬ 425-226-1266

## ធនធានផ្នែកច្បាប់

- **CLEAR** (Coordinated Legal Education Advice and Referral System): ការបំរើទូរសព្ទដោយគ្មានគិតថ្លៃ សំរាប់ជំនួយផ្នែកច្បាប់ ដោយគ្មានឈ្នួល ជាមួយនឹងរឿងរ៉ាវផ្នែកច្បាប់ស៊ីវិល ។
  888-201-1014, TTY 1-888-201-9737
- **Northwest Immigrants Rights Project,**
  206-587-4009 ឬ 800-445-5771
- **Northwest Justice Project**
  206-464-1519, www.nwjustice.org
- **Northwest Women's Law Center**
  206-621-7691

គំរោងនេះបានគាំទ្រដោយជំនួយ Grant No. 2001-WF-BX-003 ដែលជួយ ទៅដល់ Seattle Municipal Court (មន្ទីរតុលា ការក្រុងស៊ីអាថុល) ដោយ Violence Against Women Grants Office (ការិយាល័យជំនួយស្ត្រីប្រឆាំង នឹងអំពើហឹង្សា), Office of Justice Programs (កម្មវិធីការិយាល័យយុត្តិធម៌), U.S. Department of Justice (ក្រសួងយុត្តិធម៌នៃសហរដ្ឋ អាមេរិក) ។ ទស្សនៈនៅក្នុងឯកសារទាំងអស់នេះគឺជាគំនិតរបស់ អ្នកនិពន្ធ ហើយពុំមែនតំណាងជា ចាំបាច់នៅក្នុងស្ថានភាពឬច្បាប់របស់ក្រសួងយុត្តិធម៌ទេ ។

CAMBODIAN



# បើអ្នកណាម្នាក់ធ្វើឲ្យអ្នករងទុក្ខឈឺចាប់នៅផ្ទះអ្នក

## មានច្បាប់ជាច្រើនដើម្បីការពារអ្នក

ពត៌មានសំរាប់ ស៊ីអាថុល និង឴ ឃីងខោនធី , រដ្ឋវ៉ាស៊ីនតោន

## អ្វីជាអំពើហឹង្សានៅក្នុងគ្រួសារ ?

តើដៃគូរបស់អ្នក (ប្តី គូសង្សារ ឬ "អតីត") មានការ ប្រច័ណ្ឌឬទេ ? តើគេរារាំងអ្នកឲ្យនៅឆ្ងាយពីមិត្តសំឡាញ់ និងគ្រួសារ អ្នកឬទេ ? តើគេសាកល្បងរារាំងអ្នកមិនឲ្យទៅធ្វើការឬទេ ? តើគេដែលមានគំរាមកំហែងអ្នកថាគេនឹងយកកូនទាំងអស់ពីអ្នកឬទេ ? តើគេមានគំរាមកំហែងអ្នកថាឲ្យគេនិរទេសអ្នកចេញពីសហរដ្ឋឬទេ ?

តើដៃគូរបស់អ្នកធ្លាប់ដែលមានធ្វើឲ្យអ្នកឈឺចាប់ដល់រាងកាយ ជាឧទាហរណ៍ ដោយទះកំភ្លៀង រុញច្រាន ដាល់ ទាត់ ច្របាច់ក ឬបោចសក់របស់អ្នកឬទេ ? តើគេធ្លាប់ដែលគំរាមកំហែងអ្នកថានឹងសម្លាប់ ធ្វើឲ្យឈឺចាប់ ដោយប្រើអាវុធដូចជាកាំភ្លើង កាំបិត ឬវត្ថុដទៃៗ ទៀតឬទេ ? តើគេមាននិយាយប្រាប់អ្នកថា អំពើហឹង្សាទាំងអស់នេះជាកំហុសរបស់អ្នក ?

បើអ្នកឆ្លើយ បាទឬចាស៎ ទៅនឹងសំនួរទាំងអស់នេះ នោះអ្នកស្ថិតនៅក្នុងទំនាក់ទំនងដែលមានភាពរំលោភធ្វើបាប ។ អ្នកប្រហែលអាចត្រូវស្ថិតនៅក្នុងភាពគ្រោះថ្នាក់ ។ អ្នកមិនមែនមានការរងគ្រោះតែឯងទេ ។ មនុស្សជាច្រើនឯទៀត ស្ថិតនៅក្នុងលក្ខណៈដូចអ្នកដែរ ។ មានជំនួយនានានៅតាមទីភ្នាក់ងារដែលមានរាយឈ្មោះនៅក្នុងសៀវភៅស្តើងនេះ ។

ក្នុងសៀវភៅស្តើងនេះ យើងសំដៅអ្នករំលោភបំពានជាពាក្យ "គេ" ប៉ុន្តែបុគ្គលណាមួយ ប្រុសឬស្រី អាចត្រូវរំលោភបំពានដោយដៃគូរបស់គេ ។

## តើអំពើហឹង្សានៅតាមផ្ទះប្រឆាំងនឹងច្បាប់ឬទេ ?

លក្ខណៈនៃអំពើហឹង្សានៅក្នុងគ្រួសារជាច្រើន គឺប្រឆាំងនឹងច្បាប់នៅក្នុងរដ្ឋវ៉ាស៊ិនតោន ។ វាជាការខុសច្បាប់សំរាប់ដៃគូរបស់អ្នក ដែលធ្វើឲ្យអ្នកឈឺចាប់ដល់រាងកាយក្នុងរបៀបណាមួយ បង្ខំអ្នកឲ្យរួមផ្លូវភេទនៅពេលដែលអ្នកមិនចង់ គំរាមកំហែងថានឹងវាយដំ ឬសម្លាប់អ្នក ឬកូនទាំងអស់របស់អ្នក ឬបំផ្លាញទ្រព្យសម្បត្តិរបស់អ្នក ។ បើអ្នកជាជនរងគ្រោះនៃអំពើហឹង្សានៅក្នុងគ្រួសារ មានច្បាប់ជាច្រើនសំរាប់ការពាររូបអ្នក ។

## តើខ្ញុំគួរទូរសព្ទហៅប៉ូលិសឬទេ ?

បើអ្នកស្ថិតនៅក្នុងភាពគ្រោះថ្នាក់ ចូរទូរស័ព្ទ 9-1-1 ដើម្បីឲ្យប៉ូលិសជួយ ។ អ្នកនឹងត្រូវគេសួរឲ្យប្រាប់ផ្លូវអាសយដ្ឋានពិតប្រាកដ អធិប្បាយយ៉ាងច្បាស់លាស់នូវអ្វីដែលបានកើតមានឡើង កើតមានឡើងនៅពេលណា ឈ្មោះដៃគូរបស់អ្នក ថ្ងៃខែកំណើត លេខរថយន្ត និងភិនភាគរាងកាយ (ពណ៌សក់ សម្បុរស្បែក អាយុ កំពស់ ទម្ងន់) ។ អ្នកទទួលទូរស័ព្ទនឹងបញ្ជូនប៉ូលិសមកផ្ទះរបស់អ្នក ។ អ្នកអាចរង់ចាំប៉ូលិសមកដល់ ។ បើអ្នកមានអារម្មណ៍ភ័យខ្លាច ស្នើសុំឲ្យអ្នកទទួលទូរស័ព្ទកុំដាក់វាចុះ ។

បើអ្នកមិនចេះនិយាយភាសាអង់គ្លេស ចូរប្រាប់អ្នកទទួលទូរសព្ទ 911 អំពីឈ្មោះភាសាដែលអ្នកនិយាយ (ជាភាសាអង់គ្លេស) ។ អ្នកទទួល ទូរសព្ទ 911 នឹងបន្តទូរសព្ទទៅអ្នកណាម្នាក់ដែលនិយាយភាសារបស់អ្នក (នៅក្នុងបណ្តាញទូរសព្ទ AT&T) ។ នៅពេលនោះ អ្នកនឹងនិយាយជាមួយមនុស្សពីរនាក់ អ្នកបកប្រែភាសាម្នាក់ នឹងអ្នកទទួលទូរសព្ទ 911 ម្នាក់ ។

## តើនឹងមានរឿងអ្វីកើតឡើងនៅពេលដែលប៉ូលិសមកដល់ ?

នៅពេលប៉ូលិសមកដល់ គេនឹងបំបែកអ្នកចេញពីដៃគូរបស់អ្នក ហើយសួរម្នាក់ៗជាច្រើនសំនួរ ។ ចូរផ្តល់ពត៌មានឲ្យបានច្រើនបំផុតដែលអាចធ្វើទៅបានអំពីរឿងហេតុកើតឡើង ។ បើអ្នកមានរបួសឈឺចុកចាប់ បង្ហាញប្រាប់តម្រួត កន្លែងជាំ ស្នាមទានា កន្លែងដាច់ របួសឬរបួសឯទៀតៗ ។ បើដៃគូរបស់អ្នក មានធ្វើទុក្ខទោសឬបំភែអ្នកក្នុងពេលណាមួយពីមុនមក ចូរនិយាយប្រាប់ប៉ូលិសអំពីរឿងនេះ ។

អ្នកមានសិទ្ធិនឹងនិយាយប្រាប់រឿងនានាទៅប៉ូលិស ។ កូនរបស់អ្នក ដៃគូ និងសមាជិកគ្រួសារឯទៀតរបស់អ្នក **មិនគួរ** ឲ្យគេ បកស្រាយឲ្យអ្នកទេ ។ មន្ត្រីប៉ូលិសអាចទូរសព្ទរកអ្នកបកប្រែភាសា ដើម្បីបកប្រែឲ្យអ្នក ។ អ្នកអាចសរសេរអធិប្បាយនូវអ្វីដែលកើតមាន ឡើងក្នុងភាសារបស់អ្នក ហើយសុំប៉ូលិសឲ្យបញ្ចូលវាទៅក្នុងរបាយការណ៍របស់គេ ។ បើមានកាំភ្លើងនៅក្នុងផ្ទះរបស់អ្នក ចូរប្រាប់ប៉ូលិសថាវានៅកន្លែងណា ។ ព្រមទាំងស្នើសុំលេខកំណត់ហេតុនិងសរសេរវាទុកផងដែរ។

វាមិនមែនជាច្បាប់របស់ទីភ្នាក់ងារប៉ូលិសក្នុងតំបន់ ដើម្បីធ្វើសេចក្តីរាយការណ៍អំពីជនរងគ្រោះនូវអំពើហឹង្សានៅក្នុងគ្រួសារទៅក្រសួងអន្តោប្រវេសន៍និងចូលសញ្ជាតិទេ ។ បើអ្នកត្រូវគេសួរអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នក អ្នកអាចនិយាយប្រាប់ប៉ូលិសថា អ្នកមិនចង់ឆ្លើយនឹងសំនួរនេះទេ ហើយថាអ្នកត្រូវការនិយាយជាមួយនឹងមេធាវីម្នាក់ ។

## តើនឹងមានរឿងអ្វីកើតឡើង បើដៃគូរបស់ខ្ញុំត្រូវគេឃាត់ខ្លួន ?

មន្ត្រីប៉ូលិសអាចឃាត់ខ្លួនដៃគូរបស់អ្នកបាន បើគេជឿថាមានការប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម ។ បើគេនាំគាត់ដាក់ពន្ធនាគារ គាត់អាចត្រូវគេដោះលែងឲ្យរួចខ្លួនវិញក្នុងរយៈពេលពីរឬបីម៉ោង ឬគាត់អាចត្រូវគេ ឃុំឃាំងជាច្រើនថ្ងៃ ឬយូរជាងនេះ ។ អ្នកអាចទទួលដំណឹងតាមទូរសព្ទអំពី ការដោះលែងរបស់គាត់ពីពន្ធនាគារ បើសិនជាអ្នកចុះបញ្ជីជាមួយ VINE (មានសំរាប់តែពន្ធនាគារឃីងខោនធីតែប៉ុណ្ណោះ ) ដែលជាប្រពន្ធទូរស័ព្ទតាមកុមព្យូទ័រ ។ ដើម្បីចុះឈ្មោះក្នុងបញ្ជីសំរាប់ការបំរើដោយ គ្មានបង់ថ្លៃ ចូរទូរស័ព្ទទៅលេខ 1-877-425-8463 ។

## តើមានរឿងអ្វីកើតឡើងក្រោយពេលដែលដៃគូខ្ញុំបានត្រូវឃាត់ខ្លួន ?

បើដៃគូរបស់ខ្ញុំត្រូវបានឃាត់ខ្លួន សុភាចាបុរសអាចសំរេចដាក់ពាក្យចោទប្តឹងចំពោះគាត់ ។ ពុំមែនសំរេចទៅលើរូបអ្នក ចង់ចោទប្តឹងឬមិនចោទប្តឹងគាត់នោះទេ ។ មានតែសុភាចាបុរសប៉ុណ្ណោះដែលអាចធ្វើសេចក្តីសំរេចចោទប្តឹងឬមិនចោទប្តឹង ។

នៅពេលតុលាការធ្វើសវនាការជំនុំជំរះមុនដំបូង ចៅក្រមអាចចេញដីកាមួយហៅ ដីកាហាមទាក់ទង ដែលជាដីកាមិនឲ្យដៃគូរបស់អ្នកកុំឲ្យទាក់ទងអ្នក ។ បើគេទាក់ទងមកអ្នកដោយផ្ទាល់ តាមទូរស័ព្ទឬតាមសំបុត្រ អ្នកអាចទូរស័ព្ទលេខ 9-1-1 ហើយគាត់អាចត្រូវគេចាប់ឃុំឃាំងជាថ្មីទៀត ។

ដីកាហាមទាក់ទងមិនមានផ្តល់ការការពារសំរាប់កូនរបស់អ្នកទេ ។ បើអ្នកកង្វល់ពីរឿងសុវត្ថភាពកូនរបស់អ្នក ឬសំរាប់ការរៀបចំមកសួរ សុខទុក្ខ អ្នកត្រូវតែដាក់ពាក្យបណ្តឹងសំរាប់ដីកាការពារសន្តិសុខមួយ ។

## តើមានអ្វីកើតឡើង បើខ្ញុំត្រូវតែទៅឡើងតុលាការ ?

នៅក្នុងសំណុំរឿងឧក្រឹដ្ឋកម្ម គឺអាចមានសវនាការជំនុំជំរះជាច្រើនដង ។ បើមានការវិនិច្ឆ័យ អ្នកនឹងត្រូវគេប្រាប់ឲ្យដឹងតាមទូរស័ព្ទឬសំបុត្រជាលាយលក្សអក្សរថា អ្នកត្រូវបានគេរំពឹងថាទៅជួបនៅតុលាការ ។ បើបុគ្គលណាម្នាក់គំរាមកំហែងអ្នកដោយសាកល្បងឃាត់ឃាំងអ្នក មិនឲ្យអ្នកទៅតុលាការអំពើនេះគឺជាឧក្រឹដ្ឋកម្ម ហើយអ្នកអាចរាយការណ៍ទៅប៉ូលិស ។

អ្នកជួយគាំទ្រនឹងធ្វើការជាមួយអ្នក ដើម្បីជួយអ្នកក្នុងដំណើរការវិនិច្ឆ័យតុលាការ ។ សូមឲ្យប្រាកដថា អ្នកជួយគាំទ្រអាចរកអ្នកឃើញនៅកន្លែងមួយ ។ នៅតុលាការ សុភាចាបុរស និងមេធាវីរបស់កូនក្តី អាចសួរសំនួរអ្នកអំពីអំពើហឹង្សានៅ ក្នុងគ្រួសារដែលកើតឡើង ។

## តើវាមានតុលាការលើសពីមួយកន្លែងឬទេ ?

នៅក្នុងឃីងខោនធីមានតុលាការខុសៗគ្នាជាច្រើន ។ មេធាវីរបស់អ្នកនឹងពន្យល់អំពីប្រព័ន្ធតុលាការដល់អ្នក ។ តុលាការក្នុងតំបន់ (ក្រុងឬតំបន់) ជំនុំជំរះទោសមជ្ឈិម (ថ្នាក់ទាប ) ។ តុលាការជាន់ខ្ពស់ឃីងខោនធី (គិនងជឌុនតយ ស៊ុផរិឌរ ជឌុរត) ជំនុំជំរះទោស ឧក្រិដ្ឋទាំងពីរ (ទោសធ្ងន់) និងរឿងរ៉ាវទាក់ទងក្នុងគ្រួសារ ដូចជាការលែងលះគ្នា និងអាណាព្យាបាលក្មេង ។ មានដីកាសំរាប់ការពារអាចមាននៅគ្រប់តុលាការទាំងអស់នេះ ។

បើអ្នក ឬដៃគូរបស់អ្នកមានសំណុំរឿងនៅក្នុងតុលាការ ច្រើនកន្លែង សូមកុំសន្មតថា ចៅក្រមនៅក្នុងតុលាការមួយដឹងរឿងរ៉ាវ នៅក្នុងតុលាការឯទៀតឡើយ ។ តុលាការនិមួយៗធ្វើការផ្សេងៗគ្នា ។ អ្នកគួរតែនាំយកឯកសារនានាដែលទាក់ទងនឹងច្បាប់ ដោយរួមទាំងដីកាបញ្ជាការពារ និងដីកាមិនឲ្យមានការទាក់ទង ទៅគ្រប់កន្លែងធ្វើ សវនាការជំនុំជំរះ និងសូមឲ្យប្រាកដថា អ្នកគាំទ្ររបស់អ្នក ដឹងរឿងរ៉ាវរបស់អ្នកពីរឿង ឯទៀត។